ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...........សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពលើប្រការ ២ នៃប្រកាសលេខ ៥៣៨ សហវ.ប្រក ស្តីពីការបង្កើតអង្គភាពអនុវត្តគម្រោងជំនាញសម្រាប់បង្កើនភាពប្រកួតប្រជែង ដោយប្រើប្រាស់ឥណទានធនាគារអភិវឌ្ឍន៍អាស៊ី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤៦១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញប្រកាសលេខ ៤៤២ សហវ.ប្រក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៦៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០១៨ ស្តីពីការបង្កើតអង្គភាពអនុវត្តគម្រោងសាកល្បងយន្តការគ្រប់គ្រងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ ៥៣៨ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៩ ស្តីពីការបង្កើតអង្គភាពអនុវត្តគម្រោងជំនាញសម្រាប់បង្កើនភាពប្រកួតប្រជែងដោយប្រើប្រាស់ឥណទានធនាគារអភិវឌ្ឍន៍អាស៊ី
- បានឃើញប្រកាសលេខ ១០៣២ សហវ.ប្រក ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពលើប្រការ ២ នៃប្រកាសលេខ ៥៣៨ សហវ.ប្រក ស្តីពីការបង្កើតអង្គភាពអនុវត្តគម្រោងជំនាញសម្រាប់បង្កើនភាពប្រកួតប្រជែងដោយប្រើប្រាស់ឥណទានធនាគារអភិវឌ្ឍន៍អាស៊ី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារ នៃប្រកាសលេខ ៥៣៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៩ ស្តីពីការបង្កើតអង្គភាពអនុវត្តគម្រោងជំនាញសម្រាប់បង្កើនភាពប្រកួតប្រជែងដោយប្រើប្រាស់ឥណទានធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. លោក **គី សុខគីម** | អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ | ប្រធានសម្របសម្រួលគម្រោង |
| ២. លោក **ស៊ាន លីហោខ** | មន្ត្រីនៃនាយកដ្ឋានវិស័យសេដ្ឋកិច្ចថ្មី | អនុប្រធានសម្របសម្រួលគម្រោង |
| ៣. លោកស្រី **ហួត ច័ន្ទបញ្ញា** | អនុប្រធានលេខាធិការដ្ឋាន | មន្ត្រីទទួលបន្ទុកសម្របសម្រួល |
| ៤. លោក **ចន្ថា ម៉េងលី** | អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ | មន្ត្រីទទួលបន្ទុកត្រួតពិនិត្យនិងវាយតម្លៃ |
| ៥. លោក **ម៉ុណ្ណា ឧត្តម** | ប្រធានការិយាល័យនៃនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ | មន្ត្រីទទួលបន្ទុកលទ្ធកម្ម |
| ៦. លោក **ចន សុផាន់ណារ៉ាក់** | មន្ត្រីនៃនាយកដ្ឋានវិស័យសេដ្ឋកិច្ចថ្មី | មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ |
| ៧. លោកស្រី **តិរុន លក្ខិណា** | មន្ត្រីនៃនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ | មន្ត្រីទទួលបន្ទុករដ្ឋបាល |

| | | | |
|---|---|---|---|
| ៨. លោក | **ធីម ហេងលី** | មន្ត្រីនៃនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ | មន្ត្រីទទួលបន្ទុកអភិវឌ្ឍន៍ទីផ្សារ |
| ៩. លោក | **អ៊ុល ទិតីសំក្ខណៈលីឃុន** | មន្ត្រីនៃនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ | មន្ត្រីទទួលបន្ទុកពិនិត្យសំណើគម្រោង។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីជនដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែអាសាឍ ឆ្នាំថោះ បញ្ចស័ក ព. ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ